**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប**

# ព័ត៌មានស្តីពីសត្វព្រៃ
# នៅជុំវិញតំបន់ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប

## I. ព័ត៌មានទូទៅអំពីក្រុមចោរជ័រ

ក្នុងរយៈពេល៣ឆ្នាំមុនមកទល់នឹងរយៈ៤ខែមុន ក្នុងឆ្នាំ២០១៨នេះ ប្រជាជនរស់នៅក្នុងភូមិឆែបលិច ភូមិឆែបកើត និងឆែបក្រសាំង ស្រុកឆែប ខេត្តព្រះវិហារ ដែលជាអ្នកប្រកបរបរចោះជ័រក្នុងតំបន់ឆ្ងាយពីផ្ទះ ចម្ងាយប្រមាណជាជាង៤០គីឡូម៉ែត្រ (ផ្លូវកាត់នៅនារដូវប្រាំង) ឬចម្ងាយប្រមាណជាង១០០ គីឡូម៉ែត្រ (ផ្លូវវាងនៅរដូវវស្សា) តែងបានជួបដោយឥតស្វែងរកនូវហ្វូងសត្វដំរីដោយផ្ទាល់ ឬគន្លងជើងដំរី (កាលួង) អាចម៍ដំរី និងរោមដំរីដែលមានជាប់នឹងដើមឈើ ព្រមទាំងបានជួបប្រទះសត្វព្រៃផ្សេងៗទៀត ដូចជា ឆ្កែព្រៃ ចចក ទន្សោង ឈ្លូស និងខ្លាឃ្មុំ នៅក្នុងចំការចោះនិងក្បែរចំណតរបស់ពួកគេដែលស្ថិតនៅក្នុងដែនជម្រកសត្វឆែប ស្រុកជាំក្សាន ខេត្តព្រះវិហារ ដែលមានចម្ងាយពីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា ប្រមាណជា៤៥គីឡូម៉ែត្រ។ សត្វដំរី ទាំងនៅរដូវប្រាំងនឹងនៅរដូវវស្សា តែងចូលមកក្នុងតំបន់ចំការចោះជ័រ និងលុកលុយក្នុងចំណតនិងកំទេចសម្ភារៈ ចាន ឆ្នាំងរបស់ចោះជ័រ ខណៈពេលដែលពួកគាត់អវត្តមានពីចំការចោះ។ ចំណុចគោលដៅនៃវត្តមានស្លាកស្នាមគន្លងដំរី ច្រើនកើតមាននៅក្នុងតំបន់ព្រៃអភិរក្សជុំវិញភូមិរបុញ ។

## II. ប្រជាចោរជ័រដែលបានជួបដំរីនិងគន្លងដំរី

ប្រជាចោះជ័រដែលបានជួបដំរីនិងប្រទះឃើញគន្លងជើងដំរី មានដូចជា៖

-លោក ខេក ឃឿន ធ្លាប់ជួបពេលយប់ម៉ោង៩ និងបានរក្សាទុកអាចម៍ដំរី

-លោក ភន

-លោក ខុន និង ភរិយា

-លោក ពើត (ដែលមានក្រុមការងារចោះជាមួយលោក វិត, លោក ខៀន)

-លោក ស សុខណា យើងមិនបានសម្ភាសគាត់ផ្ទាល់ព្រោះគាត់ចេញទៅចោះ ប៉ុន្តែយើងទទួលព័ត៌មានពីកូនប្រុស ដែលធ្លាប់ទៅចោះជាមួយឪពុក និងជួបដំរី ពេលថ្ងៃ។

-លោក រិន អឿត

-លោក រឿន ខៃ មានក្រុមការងារជាមួយលោក ជីន លោក អាន និង លោក ម៉ៅ ។ យើងមិនបានសម្ភាសគាត់ផ្ទាល់ព្រោះគាត់ចេញទៅចោះ ប៉ុន្តែយើងទទួលព័ត៌មានពីប្រពន្ធ(ធ្លាប់មានដំរីរុះរើចានឆ្នាំង) ។

លោក ភីន បានជួបនឹងហ្វូងសត្វដំរីដែលមានចំនួន៥ក្បាល ដំរីធំ៤ក្បាល និងកូន១ក្បាល។ លោក ភីន មានក្រុមការងារជាមួយលោក រឿង ឃឿ, ហួន លឿត និង រ៉េម វង់ ដែលជាអ្នកបានជួបដំរី។

### III. ខ្លឹមសារបទសម្ភាសជាមួយអ្នកដែលបានជួបដំរីនិងគន្លងដំរី

#### ១-លោក ខេក ឃឿន

*-បទសម្ភាសន៍ជាមួយលោក ខេក ឃឿន ដែលជាអ្នកបានជួបដានសត្វដំរី*

គាត់បានឃើញគន្លងដំរីមានតូចមានធំ នៅភូមិបុញ្ញ ស្រុកជាំក្សាន្ត នៅក្នុងដែនជម្រកសត្វឆែប នៅខាងកើតព្រៃព្រះរការ។ អ្នកច្បោះជ័រនៅភូមិឆែបកើត ឈ្មោះ ខុន បានដើរប៉ះដំរីម្តងៗដែរ នៅពេលឥឡូវនេះ។ នៅខែប្រាំងយើងជិះម៉ូតូទៅចេញតាមដងផ្លិត តាមវាលចាកៅ ដល់អូរគគីរ នៅខែវស្សាជិះគោយន្តទៅតាមស្រទៀ តែកន្លះថ្ងៃដល់។ កាលពីខែប្រាំង ឆ្នាំនេះ គាត់បានយកអាចម៍ដំរីមកផ្ទះ ដើម្បីដាក់លាយជាមួយទឹកឱ្យសត្វមាន់ផឹកការពារជំងឺ។ គាត់បានឃើញឈ្លូស និងទន្សោងមានច្រើន ប៉ុន្តែមិនបានឃើញសត្វខ្ទីងនិងសត្វខ្លាទេ។ សត្វដំរីស៊ីព្រិច វល្លិ៍តាអាន និងចុងផ្តៅ។ អ្នកផ្សេងទៀតដែលបានជួបដំរីដែរ គឺឈ្មោះ *លី* រស់នៅភូមិឆែបកើត។





#### ២-ភរិយា លោក ខុន

*-បទសម្ភាសន៍ជាមួយប្រពន្ធ លោក ខុន ដែលជាអ្នកបានជួបសត្វដំរី*

បងស្រីបាននិយាយថា គាត់ទៅច្បោះជ័រជាមួយប្តី បានជួបនិងឮសម្លេងសត្វដំរីស្រែក «លាសៗ» តែពេលយប់នៅពេលវាដើរកាត់ក្បែរចំណតចំការច្បោះចម្ងាយពីគ្នាប្រមាណ២០០ម ប៉ុន្តែមិនដឹងធំឬតូចទេ ឃើញតែដានជើងធំប៉ុនថ្លាំង និងមានតូចខ្លះនិងធំខ្លះ។ ពេលខ្លះនៅពេលយើងមិននៅវាទាញកៅស៊ូចំណតចេញ។ គាត់បានឃើញដានជើងដំរីទាំងក្នុងខែប្រាំងនិងខែវស្សា។ នៅក្នុងព្រៃ ដំរីដើរជាលក្ខណៈធម្មតាព្រោះវាសាំងជាមួយនឹងមនុស្សហើយ។ ពីឆ្នាំទៅ (២០១៧) ប្តីរបស់គាត់គំបង់តែដងជ័រក៏ស្រាប់តែពើបដំរី។ ចេញពីផ្លូវចូលទៅព្រៃច្បោះរបស់គាត់មិនឆ្ងាយប៉ុន្មានទេ ប្រហែលជា២-៣គីឡូម៉ែត្រ។ ដំរីជាទូទៅ អ្នកច្បោះជ័រតែងបានជួបស្ទើរគ្រប់គ្នា ព្រោះវានៅគ្រប់ច្រក។ ដំរីនោះមានចំនួនប្រមាណជាពី៦-៧ក្បាល។ តាមគន្លងរបស់វា ជួនកាលវាដើរជាហ្វូង ជួនកាលវាដើរតែម្នាក់វា នៅក្នុងទីតាំងចំការច្បោះរបស់គាត់ដែលមិនសូវមានព្រៃ ជាទីវាលៗ។ ដំរីនោះ ទំនងជាធ្វើដំណើរឆ្លងកាត់ទៅមកពីទឹកដីលាវផងដែរ។ នៅខែវស្សាធ្វើដំណើរមកទឹកដីកម្ពុជា។ ក្រៅពីដំរី គាត់បានជួបតែសត្វជ្រូកព្រៃ និងមិនដែលបានជួបសត្វខ្លា និងសត្វឈ្លូសទេ។ គាត់ធ្លាប់ឃើញតែគន្លងជើង (កាលួង)ទន្សោង ស្រដៀងគ្នានឹងដានជើងគោ។ នៅទីនោះមិនមានភូមិអ្នកស្រុកទេ។ គាត់មិនស្គាល់តំបន់ភូមិបុញ្ញទេ។ ចំការច្បោះរបស់គាត់នៅម្តុំមុខត្រពាំងម្រាក់ទេរ កៀកក្បែរនឹងភូមិដងផ្លិត។ ដំរីដែលគាត់ជួបគឺនៅម្តុំអូរគគីរ ។ នៅក្នុងចំការច្បោះ យើងដើរទៅទៅណាក៏ជួបអាចម៍ដំរីដែរ។ កាលពីឆ្នាំទៅ គាត់បានវេចអាចម៍ដំរីមកផ្ទះ ប៉ុន្តែឥឡូវមិនដឹងទុកនៅទីណាទេ។ បើសួរលោក រឿន ខៃ និងលោក ស សុខណា នឹងដឹងច្រើន។

#### ៣-លោក ស សុខណាត កូនលោក ស សុខណា

*-បទសម្ភាសន៍ជាមួយកូន លោក ស សុខណា ដែលធ្លាប់ទៅច្បោះជ័រជាមួយឪពុក*

គាត់ធ្លាប់ឮស្នូរដំរីហ្វូងឆ្លងកាត់ចំការចេ្បាះរបស់គាត់ ម្តងទៅពីរដង នៅចម្ងាយពីគ្នាប្រមាណ៣០០ម នៅវេលាប្រហែលម៉ោង៩-១០ យប់។ ហ្វូងដំរីមានចំនួន៤ក្បាលធំៗ ប៉ុន្តែមិនធំប៉ុនគ្នាទាំងអស់ទេ។ គាត់ក៏ធ្លាប់ជួបដំរីធំ១ដែលបែកហ្វូង ដើរតែឯង កម្ពស់ប្រហែលជាជាង២ម៉ែត្រ នៅវេលាម៉ោង១២ថ្ងៃ នៅត្រង់តំបន់ចេ្បាះដ័រ ភូមិចាស់របុញតែម្តងកាលពីខែប្រាំងឆ្នាំ២០១៧។ គាត់ធ្លាប់ឃើញអាចម៍ដំរីនៅក្នុងព្រៃ ប៉ុន្តែមិនបានយកមកផ្ទះទេ។ ក្រុមអ្នកចេ្បាះដ័រដែលបានឃើញដំរីជាមួយគ្នានោះ រួមមានឈ្មោះ លោក លៀម លោក ពឿត។ ការធ្វើដំណើរដោយគោយន្តទៅចេ្បាះ ចេញពីឆែបទៅនៅម៉ោង៧ព្រឹក នឹងដល់ភូមិរបុញ នៅម៉ោង២ឬ៣ រសៀល។ បន្តដំណើរទៅដល់ចំការចេ្បាះនឹងចំណាតរយៈផ្លូវ ប្រមាណជា១០គីឡូម៉ែត្រ។ គោយន្តនឹងស៊ីសាំងចំនួន១៥លីត្រទាំងទៅទាំងមក។ គាត់មិនធ្លាប់ជួបសត្វខ្លាទេហើយក៏មិនដែលឃើញអាចម៍ខ្លា រួមទាំងខ្ទីងនិងទន្សោងដែរ ប៉ុន្តែធ្លាប់ជួបសត្វឈ្លូស។ គាត់ធ្លាប់ជួបក្ងោកនិងត្រដក់។



## ៤-ភរិយា លោក រឿន ខៃ



*-បទសម្ភាសន៍ជាមួយ ប្រពន្ធ លោក រឿន ខៃ ខណៈដែលប្តីគាត់បានចេញទៅចេ្បាះប្រើក្នុងរយៈពេល២០ថ្ងៃ*

គាត់បានរៀបរាប់សំដីប្តីគាត់ដែលបានប្រាប់គាត់ថា សត្វដំរីបានរុះរើជាន់កំទេចចាន ឆ្នាំង របស់គាត់ កាលពីខែមិនា- មេសា ឆ្នាំ២០១៨នេះ។ នៅចំការចេ្បាះរបស់គាត់ ដំរីច្រើនតែចូលមកនៅខែប្រាំង។ គាត់មិនធ្លាប់យកអាចម៍ដំរីមកផ្ទះទេ។

## ៥-លោក អាន

*-បទសម្ភាសន៍លោក អាន (ក្រុមការងារជាមួយគ្នានឹង លោកជី និងលោក ម៉ៅ លោក រឿន ខៃ)*

លោក អាន បានរៀបរាប់អំពីសកម្មភាពដំរីចូលមករុះរើរបស់របរចាន ឆ្នាំង កានទឹក ព្រមទាំងហែកអាវនិងមុងនៅក្នុងចំណតចេ្បាះរបស់គាត់ នៅពេលគាត់ទុកចោលចំណតរបស់គាត់។ គាត់មិនធ្លាប់ជួបដំរីផ្ទាល់ទេ ប៉ុន្តែធ្លាប់បានឃើញតែគន្លងដំរី នៅពេលគាត់ធ្វើដំណើរទៅចេ្បាះដ័រនៅក្បែរចំណតចេ្បាះ។ គាត់ជួបដានគន្លងដំរីទាំងនៅរដូវប្រាំងនិងរដូវវស្សា ដោយសារដំរីដើរចល័តរហូត។ នៅខែវស្សាដំរីច្រើនដើរបៀតៗនឹងចំណតចេ្បាះ។ កាលពីឆ្នាំទៅ ឆ្នាំ២០១៧ ដំរីបានមកនៅខាងលិច បៀតគ្នានឹងចំណត ពេលគាត់ទះធុងវាក៏ចេញទៅ។ ដំរីទាំងនោះ មិនមានច្រើនទេ ប្រហែលជា៤-៥ប៉ុណ្ណោះ។ ដំរីវាដើររហូត មិនថាយប់ឬថ្ងៃ ទាំងខែប្រាំងនិងខែវស្សា។ គាត់ឃើញអាចម៍ដំរី ប៉ុន្តែមិនធ្លាប់យកវាមកផ្ទះទេ។ គាត់ធ្លាប់បេះរោមដំរីដែលនៅជាប់នឹងដើមឈើ





បានពីរបីសរសៃ យកមកដាក់ហោប៉ៅហើយក៏ចោលបាត់ទៅ។ ដំរីច្រើនត្រដុសពីលើកូនឈើត្បែង ឬដកវំលើងកូនឈើទំហំប៉ុនសរសេរតូចៗ ឬពិតបុកដើមឈើដួលរាល។ វិធីចំណាំ បើមានកូនត្បែងដួលរលំចេញឬស នោះបង្ហាញថាមានដំរីត្រដុសហើយ។ អ្នកស្រុកមានជំនឿថា គេយករោមដំរីដែលជាប់ដើមឈើមកឱ្យកូនក្មេង។ ក្រៅពីដំរី គាត់ក៏បានធ្លាប់ឃើញគន្លងខ្ទីងនិងទន្សោង ។ គាត់ឃើញគន្លងទន្សោងនៅពេលព្រឹក សឹងតែរាល់ថ្ងៃ ខណៈដែលគាត់ចេញទៅច្បោះ។ គាត់ចំណាំគន្លងសត្វទន្សោង ស្រដៀងឬដូចគ្នាទៅនឹងគន្លងសត្វគោដែរ ប៉ុន្តែនៅទីនោះ គ្មានគោអ្នកស្រុកទេ ព្រោះជាព្រៃឆ្ងាយពីភូមិរបុញ។ ហើយបើជិះគោយន្តពីផ្លូវគ្រួសក្រហមទៅចំណតច្បោះ ត្រូវចំណាយពេលជិត១ម៉ោង។ កាលឆ្នាំទៅមួយ គឺឆ្នាំ២០១៦ គាត់បានឃើញសត្វទន្សោងទាំងហ្វូង ។ ចំពោះខ្លាវិញ គាត់មិនដែលជួបទេ សូម្បីតែដានជើងក៏មិនឃើញដែរ។ ចំការច្បោះគាត់មិនឃើញមានឆ្កែព្រៃទេ។ ប៉ុន្តែសត្វឆ្កែចចក និងសត្វក្ងោក ធ្លាប់ឃើញនិងនៅមាន។

## ៦-លោក ភីន



*-បទសម្ភាសន៍លោក ភីន* (សព្វថ្ងៃពិការជើងឆ្វេង)ធ្លាប់ជួបដំរីហ្វូងសត្វដំរីផ្ទាល់ ដែលមានចំនួន៥ក្បាល ដំរីធំ៤ក្បាល និងកូន១ក្បាល។ គន្លងដំរីធំៗ ដែលទំហំរបស់វាអាចឱ្យមនុស្សចាស់ម្នាក់អង្គុយចុះទៅក្នុងបាន។ លោកបានជួបហ្វូងដំរីនេះ កាលពី២ឆ្នាំមុន នៅក្នុងរដូវវស្សាក្នុងខែកញ្ញា វេលាម៉ោង៥:៣០នាទីទៅម៉ោង៦ល្ងាច នៅចំណុចចំការច្បោះអូរគគីរ។ ពេលគាត់ជួប គាត់បានរត់ឡើងដើមឈើកម្ពស់ប្រហែល៤ម៉ែត្រ ដែលមើលទៅទើបតែស្មើនឹងកម្ពស់ខ្នងរបស់ដំរីធំទាំង៤ក្បាល។ ដំរីទាំងនោះហាក់ដូចជាសាំងជាមួយនឹងមនុស្សហើយ ដោយសារហ្វូងរបស់វាបានជួបជាមួយមនុស្សច្រើនដង។ នៅពេលដែលហ្វូងរបស់ដំរីដឹងសន្ធឹកមនុស្ស ពួកវាគេចខ្លួនចេញពីមនុស្ស។ បើទោះជាជួបវាក់ជាមួយនឹងមនុស្ស សត្វដំរីក៏មិនធ្វើអ្វីដល់មនុស្សទេ។ គាត់មិនធ្លាប់យកអាចម៍ដំរីមកផ្ទះទេ ព្រោះវាមានទម្ងន់ធ្ងន់ប្រមាណជា២-៣គីឡូក្រាម ក្នុងមួយដុំ។ ក្រៅពីដំរី លោកភីន ក៏ធ្លាប់ជួបនឹងសត្វទន្សោង ខ្ទីងផងដែរ។ ទន្សោងដែលគាត់បានជួបផ្ទាល់ ទាំងហ្វូង ជួនកាលដើរឯង កាលពី១ឆ្នាំ។ គាត់បានឮស្នូរទន្សោងនិងខ្ទីងរត់។ ចំពោះខ្លាឃ្មុំ យូរៗម្តងគាត់បានប្រទះឃើញដានជើងរបស់វា។ គាត់ធ្លាប់ជួបតែសត្វចចកនិងខ្លាឃ្មុំ។ គាត់គិតថា ខ្លាធំអាចមានតែវានៅឆ្ងាយពីកន្លែងមនុស្ស។ កាលពីឆ្នាំ២០១២ គាត់បានឃើញគន្លងខ្លាធំនៅម្តុំអូរគគីរ។

## IV.សន្និដ្ឋាន

បើទោះជាតំបន់ច្បោះដ័រមានទីតាំងផ្សេងគ្នាក៏ដោយ ក៏ភាគច្រើននៃអ្នកប្រកបរបរច្បោះជ័រនៅជុំវិញតំបន់ភូមិចាស់របុញដែលមានព្រៃក្រាស់ សុទ្ធតែបានប្រទះឃើញដានគន្លង (កាល្បង)ដំរីនិងបានឮស្នូរដំរី ព្រមទាំងសកម្មភាពដំរីរុះរើរបស់របរក្នុងចំណតច្បោះរបស់ពួកគេ ក្នុងរយៈពេល១ទៅ៣ឆ្នាំមុន និងឆ្នាំថ្មីៗ។ ហើយនេះបង្ហាញថាសត្វដំរីបានធ្វើដំណើរចល័តគ្រប់ទីតាំងក្នុងព្រៃច្បោះ។ យ៉ាងហោចណាស់ មានសត្វដំរីចំនួនពី៤-៥ក្បាល ដែលត្រូវបានគេប្រទះជួបនៅក្នុងព្រៃ ហើយនិងមានអ្នកច្បោះជ័រចំនួន៧នាក់ដែលបានធ្លាប់ជួបដំរីដោយផ្ទាល់និងពីចម្ងាយ ដែលក្នុងនោះមាន

លោក ខុន, លោក ស សុខណា, លោក ស សុខណាត, លោក លៀម, លោក ពឿត, លោក អាន, និងលោក ភីន។ មានអ្នកច្បោះដំរីតែពីនាក់គត់ដែលបានចាប់អារម្មណ៍ចំពោះអាចម៍ដំរីនិងបាននាំយកវាមកផ្ទះ។ អ្នកខ្លះបានបេះរោមដំរីពីដើមឈើ។ ដោយសារតែតំបន់ព្រៃច្បោះគ្នាមានទីតាំងនៅខុសៗគ្នា ក្រៅពីសត្វដំរី អ្នកច្បោះដំរីខ្លះបានជួបប្រទះសត្វព្រៃមួយចំនួនដូចជា៖ សត្វខ្ទីង ឈ្លូស ទន្សោង ខ្លាឃ្មុំ ឆ្កែចចក ក្ងោក និងត្រដក់ ក្នុងនោះមាន លោក ខេក យឿន បានជួបសត្វឈ្លូស ទន្សោង; ភរិយា លោក ខុន បានជួប ទន្សោង; លោក ស សុខណាត បានជួប ឈ្លូស ក្ងោក និងត្រដក់; លោក អាន បានជួប សត្វខ្ទីង ទន្សោង ឆ្កែចចក និងក្ងោក; លោក ភីន បានជួប សត្វខ្ទីង ទន្សោង ឆ្កែចចក និង ខ្លាឃ្មុំ។ គួរឱ្យសោកស្តាយ ភាគច្រើននៃអ្នកច្បោះដំរីមិនធ្លាប់ជួបសត្វខ្លាធំទេ ប៉ុន្តែលោក ភីន គិតថា ខ្លាធំអាចនៅមានសល់ ប៉ុន្តែនៅក្នុងព្រៃឆ្ងាយពីភូមិមនុស្ស ដោយសារតែកាលពីឆ្នាំ២០១២ គាត់បានឃើញគន្លងខ្លាធំ នៅម្តុំអូរគេគីរ។

## ផែនទីស្តីពីតំបន់ព្រៃដំរីឆ្លងកាត់និងរស់នៅ

